# សាក្សីមួយរូប

*ដោយប្រធាន ហិនរី ប៊ី អាវរិង*
*ទីប្រឹក្សាទីមួយនៅ ក្នុងគណៈប្រធានទីមួយ*

ខ្ញុំមានអំណរគុណចំពោះឱកាសដើម្បីនិយាយទៅកាន់អ្នកក្នុងថ្ងៃសីល៍នេះ ក្នុងសន្និសីទទូទៅ នៃសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ សមាជិកសាសនាចក្រគ្រប់រូប មានកាតព្វកិច្ចដ៏ពិសិដ្ឋដូចគ្នា ។ យើងបានទទួលយក និង សន្យាថា ក្រោកឈរឡើងធ្វើវានៅពេលយើងបានទទួលបុណ្យជ្រមុជទឹក ។ យើងរៀនមកពីពាក្យសម្ដីរបស់អាលម៉ា ដែលជាព្យាការីព្រះគម្ពីរមរមនដ៏មហិមា នូវអ្វីដែលយើងបានសន្យានឹងព្រះថា យើងនឹង ៖ « យល់ព្រមទួញយំជាមួយនឹងអ្នកណាដែលទួញយំ មែនហើយ ហើយកំសាន្តទុក្ខដល់អស់អ្នកណា ដែលកំពុងត្រូវការកំសាន្តទុក្ខ ហើយឈរជាសាក្សីដល់ព្រះ នៅគ្រប់ពេល និងគ្រប់សេចក្ដី និង គ្រប់ទីកន្លែង ដែលអ្នករាល់គ្នាបាននៅ រហូតដល់ពេលស្លាប់ ដើម្បីឲ្យអ្នករាល់គ្នាអាចបានប្រោសលោះ ដោយព្រះ ហើយបានរាប់ជាមួយនឹងពួកអ្នកនៃដំណើររស់ឡើងវិញទីមួយ ដើម្បីឲ្យអ្នករាល់គ្នាអាចមានជីវិតដ៏នៅអស់កល្បជា-និច្ច » ។[1]

នោះគឺជាកាតព្វកិច្ចដ៏ពិសិដ្ឋ និង ជាការសន្យាដ៏រុងរឿងមួយមកពីព្រះ ។ សារលិខិតខ្ញុំថ្ងៃនេះ គឺជាសារលិខិតលើកទឹកចិត្ត ។ ដូចព្រះគម្ពីរមរមន បានប្រាប់យ៉ាងច្បាស់ដល់យើង ក៏បានប្រាប់ផ្ទាល់ដល់យើងឲ្យឆ្ពោះទៅមុខលើផ្លូវនៃជីវិតដ៏នៅអស់កល្បជានិច្ចផងដែរ ។

ទីមួយ យើងបានសន្យាថានឹងមានចិត្តសប្បុរស ។ ទីពីរ យើងបានសន្យាធ្វើជាសាក្សីរបស់ព្រះ ។ និងទីបី យើងបានសន្យាថាប្រកាន់ខ្ជាប់ ។ ព្រះគម្ពីរមរមន គឺជាមគ្គុទេសន៍ដ៏ល្អបំផុត ដើម្បីដឹងថាយើងកំពុងធ្វើបានល្អប៉ុណ្ណា ហើយធ្វើបានកាន់តែល្អដោយរបៀបណា ។

ចូរយើងចាប់ផ្ដើមជាមួយនឹងការមានចិត្តសប្បុរស ។ ខ្ញុំនឹងរំឭកអ្នកអំពីបទពិសោធន៍ថ្មីៗនេះ ។ អ្នករាល់គ្នាជាច្រើនបានចូលរួមក្នុងថ្ងៃបម្រើ ។ មានថ្ងៃបម្រើរាប់ពាន់ថ្ងៃបានរៀបចំនៅទូទាំងពិភពលោក ។

ក្រុមប្រឹក្សានៃបងប្អូនពួកបរិសុទ្ធរបស់អ្នក បានអធិស្ឋានដើម្បីដឹងថាត្រូវរៀបផែនការបម្រើណាមួយ ។ ពួកគាត់បានទូលសួរដល់ព្រះដើម្បីដឹងថា យើងគួរបម្រើដល់នរណា ថាត្រូវផ្ដល់ការបម្រើអ្វីខ្លះ ហើយអញ្ជើញនរណាឲ្យចូលរួម ។ ពួកគាត់ក៏បានអធិស្ឋានថា កុំឲ្យភ្លេចយកប៉ែល ឬ ទឹកបរិភោគផងដែរ ។ សំខាន់ជាងនោះ ពួកគាត់បានអធិស្ឋាន សុំឲ្យអស់អ្នកដែលផ្ដល់ការបម្រើ និង អស់អ្នកទទួលការបម្រើនឹងបានដឹងអំពីក្ដីស្រឡាញ់របស់ព្រះ ។ យ៉ាងហោចណាស់ ខ្ញុំដឹងថាការអធិស្ឋានទាំងនោះ បានទទួលចម្លើយនៅក្នុងវួដមួយ ។ មានសមាជិកច្រើនជាង 120 នាក់បានស្ម័គ្រចិត្តជួយ ។ ពួកគេបានសម្អាតទីធ្លាអគារព្រះវិហារមួយក្នុងសហគមន៍របស់យើងក្នុង រយៈពេលបីម៉ោង ។ វាគឺជាកិច្ចការធ្ងន់ និងរីករាយ ។ អ្នកគង្វាលនៃព្រះវិហារនោះមានការដឹងគុណ ។ អ្នកទាំងអស់ដែលបានធ្វើការជាមួយគ្នាក្នុងថ្ងៃនោះ មានអារម្មណ៍សាមគ្គីភាព និង ក្ដីស្រឡាញ់កាន់តែច្រើន ។ អ្នកខ្លះក៏បាននិយាយថា ពួកគេមានក្ដីអំណរ នៅពេលពួកគេដកស្មៅ និងតម្រឹមដើមឈើ ។

ពាក្យសម្ដីមកពីព្រះគម្ពីរមរមន បានជួយពួកគេឲ្យដឹងថាហេតុអ្វី ។ គឺជាស្ដេចបេនយ៉ាមីន ដែលបានមានបន្ទូលទៅកាន់ប្រជាជនទ្រង់ថា «… អ្នករាល់គ្នាអាចបានដឹងថា កាលណាអ្នករាល់គ្នានៅក្នុងការម្រើដល់មនុស្សទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបម្រើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ» ។[2] ហើយមរមនបានបង្រៀនក្នុងព្រះគម្ពីរមរមនដោយពាក្យនេះថា « សេចក្ដីសប្បុរស គឺជាសេចក្ដីស្រឡាញ់ដ៏សុទ្ធសាធ នៃព្រះ គ្រីស្ទ ហើយស្ថិតស្ថេរនៅជានិច្ច ហើយអស់អ្នកណាដែលមានសេចក្ដីសប្បុរស នៅក្នុងថ្ងៃចុងក្រោយបង្អស់ នឹងបានស្រួលដល់អ្នកនោះហើយ » ។[3]

ព្រះអម្ចាស់កំពុងរក្សាការសន្យារបស់ទ្រង់ចំពោះអ្នក នៅពេលអ្នករក្សាការសន្យាអ្នក ។ នៅពេលអ្នកបម្រើអ្នកដទៃសម្រាប់ទ្រង់ នោះទ្រង់នឹងឲ្យអ្នកដឹងពីក្ដីស្រឡាញ់របស់ទ្រង់ ។ ជូនកាល អារម្មណ៍នៃសេចក្ដីសប្បុរស ក្លាយជាចំណែកមួយនៃខ្លួនអ្នក ។ ហើយអ្នកនឹងទទួលអារម្មណ៍អះអាងពីមរមនក្នុងចិត្តអ្នក នៅពេលអ្នកបន្តនៅក្នុងការបម្រើដល់អ្នកដទៃក្នុងជីវិត នោះអ្វីៗទាំងអស់នឹងបានស្រួលដល់អ្នក ។ ដូចគ្នាដែលអ្នកបានសន្យាចំពោះព្រះថាកាន់តែមានចិត្តសប្បុរស នោះអ្នកបានសន្យាថា ធ្វើជាសាក្សីរបស់ទ្រង់គ្រប់ទីកន្លែងនៅក្នុងជីវិតរបស់អ្នក ។ ជាថ្មីម្ដងទៀត ព្រះគម្ពីរមរមន គឺជាមគ្គុ-ទេសន៍ដ៏ល្អបំផុត ដែលខ្ញុំដឹង ដើម្បីជួយយើងរក្សានូវការសន្យានោះ ។

មានម្ដងនោះ ខ្ញុំត្រូវបានអញ្ជើញឲ្យឡើងនិយាយនៅក្នុងការបញ្ចប់វគ្គការបម្រើ នៅសាកលវិទ្យាល័យមួយ ។ នាយកសាលាចង់អញ្ជើញប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ប៉ុន្តែគាត់ជាប់រវល់ ។ ជាលទ្ធផល ខ្ញុំក៏ទទួលការអញ្ជើញ ។ ខ្ញុំ ជាសមាជិកជុញ្ញ័រក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ ។

អ្នកដែលបានអញ្ជើញខ្ញុំឲ្យឡើងនិយាយ មានចិត្តអន្ទះសារ នៅពេលគាត់បានដឹងច្រើនអំពីការហៅរបស់ខ្ញុំក្នុងនាមជាសាវក ។ គាត់បានទូរស័ព្ទមកខ្ញុំនិយាយថា ឥឡូវ គាត់យល់ហើយថា កាតព្វកិច្ច របស់ខ្ញុំ គឺត្រូវធ្វើជាសាក្សីមួយរូបរបស់ ព្រះយេស៊ូវគ្រីស្ទ ។

គាត់ប្រាប់ខ្ញុំដោយសម្លេងម៉ឺងម៉ាត់ ដែលខ្ញុំពុំអាចធ្វើដូចពេលខ្ញុំនិយាយ ។ គាត់បានពន្យល់ថា សាកលវិទ្យាល័យគោរពមនុស្សគ្រប់ជំនឿសាសនាទាំងអស់ រួមទាំងអ្នកបដិសេធថា ព្រះមានព្រះជន្មផងដែរ ។ គាត់បាននិយាយឡើងវិញថា « អ្នកពុំអាចបំពេញកាតព្វកិច្ចរបស់អ្នកនៅទីនេះបានទេ » ។

ខ្ញុំបានបិទទូរស័ព្ទដោយមានចម្ងល់ខ្លាំងក្នុងចិត្ត ។ តើខ្ញុំគួរប្រាប់ទៅសាកលវិទ្យាល័យថា ខ្ញុំនឹងពុំព្រមនិយាយឬទេ ? មានតែប៉ុន្មានសប្ដាហ៍ប៉ុណ្ណោះមុននឹងព្រឹត្តការណ៍នោះចាប់ផ្ដើម ។ វត្តមានរបស់ខ្ញុំនៅទីនោះបានប្រកាសរួចទៅហើយ ។ តើនឹងមានឥទ្ធិពលអ្វីខ្លះ ទៅលើនាមល្អនៃសាសនាចក្រ បើខ្ញុំពុំរក្សាកិច្ចព្រមព្រៀងរបស់ខ្ញុំនោះ ? ខ្ញុំបានអធិស្ឋាន ដើម្បីដឹងនូវអ្វីដែលព្រះសព្វព្រះទ័យឲ្យខ្ញុំធ្វើ ។ ចម្លើយបានតប ។ ខ្ញុំបានដឹងថា គំរូរបស់នីហ្វៃ អ័ប៊ីណាដៃ អាលម៉ា អាមូលេក និង បុត្រារបស់ ម៉ូសាយ បានជះឥទ្ធិពលមកលើខ្ញុំ ថាជានរណាពេលនោះ ។ ពួកគេ គឺជាសាក្សីដ៏មុតមាំរបស់ព្រះយេស៊ូវគ្រីស្ទ នៅពេលប្រឈមមុខនឹងគ្រោះដល់ស្លាប់ ។

ដូច្នេះ ជម្រើសតែមួយគឺត្រូវរៀបចំយ៉ាងណា ។ ខ្ញុំបានស្រាវជ្រាវអ្វីៗគ្រប់យ៉ាង តាមលទ្ធភាពដើម្បីរៀនអំពីសាកលវិទ្យាល័យនោះ ។ នៅពេលថ្ងៃឡើងនិយាយជិតមកដល់ខ្ញុំកាន់តែអន្ទះសារ ហើយខ្ញុំបានអធិស្ឋានកាន់តែខ្លាំង ។

ខ្ញុំបានរកឃើញអត្ថបទព័ត៌មានមួយ ប្រៀបដូចជាសមុទ្រក្រហមញែកជាពីរ ។ សាកលវិទ្យាល័យ បានគោរពចំពោះអ្វីដែលសាសនាចក្របានរៀនធ្វើនៅក្នុងកិច្ចការសប្បុរសធម៌របស់យើងនៅទូទាំងពិភពលោក ។ ដូច្នេះនៅក្នុងសុន្ទរកថារបស់ខ្ញុំ ខ្ញុំបានពិពណ៌នាអំពីអ្វីដែលយើង និងពួកគេបានធ្វើដើម្បីសម្រាលដល់មនុស្សដែលកំពុងតែទុរគតិខ្លាំង ។ ខ្ញុំបាននិយាយថា ខ្ញុំដឹងថា ព្រះយេស៊ូវគ្រីស្ទ គឺជាប្រភពនៃពរជ័យទាំងអស់ ដែលមានមកក្នុងជីវិតរបស់អ្នកទាំងឡាយ ដែលយើង និង ពួកគេបានបម្រើនោះ ។

បន្ទាប់ពីការប្រជុំ ទស្សនិកជនបានក្រោកឈរទះដៃ ។ ខ្ញុំអស្ចារ្យក្នុងចិត្ត ប៉ុន្តែខ្វល់បន្តិច ។ ខ្ញុំបានចាំនូវអ្វីដែលបានកើតឡើងចំពោះអ័ប៊ីណាដៃ ។ មានតែអាលម៉ាប៉ុណ្ណោះ ដែលទទួលយកសាក្សីរបស់គាត់ ។ ប៉ុន្តែនៅយប់នោះ នាអាហារពេលល្ងាចជាផ្លូវការធំមួយ ខ្ញុំបានឮនាយកសាកលវិទ្យាល័យបាននិយាយថា នៅក្នុងសុន្ទរកថាខ្ញុំ គាត់បានឮពាក្យបន្ទូលរបស់ព្រះ ។

ការរំដោះប្រកបដោយអព្ភូតហេតុមួយដូច្នេះ គឺមានដោយកម្រនៅក្នុងបទពិសោធន៍ខ្ញុំក្នុងនាមជាសាក្សីរបស់ព្រះគ្រីស្ទ ។ ប៉ុន្តែឥទ្ធិពលព្រះគម្ពីរ មរមនទៅលើចរិតលក្ខណៈ អំណាច និងភាពក្លាហានរបស់អ្នកដើម្បីធ្វើជាសាក្សីរបស់ព្រះ គឺមានពិតមែន ។ គោលលទ្ធិ និង គំរូដ៏អង់អាច នៅក្នុងគម្ពីរនោះនឹងលើកអ្នកឡើង ដឹកនាំអ្នកហើយលើកទឹកចិត្តដល់អ្នក ។
អ្នកផ្សព្វផ្សាយសាសនាគ្រប់រូប ដែលប្រកាសព្រះនាម និង ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ នឹងបានពរ តាមរយៈការទទួលទានមកពីព្រះគម្ពីរមរមនជាប្រចាំ ។ ឪពុកម្ដាយ ដែលពុះពារដើម្បីដាក់ទីបន្ទាល់អំពីព្រះអង្គសង្គ្រោះនៅក្នុងដួងចិត្តរបស់កូន នឹងទទួលបានជំនួយ នៅពេលពួកគាត់ព្យាយាមរកផ្លូវមួយ ដើម្បីនាំពាក្យ និង ឥទ្ធិពលនៃព្រះគម្ពីរមរមន ចូលក្នុងគេហដ្ឋាន និង ក្នុងជីវិតរស់នៅរបស់មនុស្សទាំងអស់ក្នុងគ្រួសារពួកគាត់ ។ នោះបានបញ្ជាក់ការពិតសម្រាប់យើង ។

ខ្ញុំអាចឃើញថា អព្ភូតហេតុកំពុងតែកើតមានក្នុងគ្រប់ការប្រជុំសាក្រាម៉ង់ និង ថ្នាក់រៀនក្នុងសាសនាចក្រដែលខ្ញុំចូលរួម ។ អ្នកឡើងនិយាយ និង គ្រូបង្រៀន បង្ហាញសេចក្ដីស្រឡាញ់ និង ការយល់ដឹងច្រើនអំពីព្រះគម្ពីរ ជាពិសេស ព្រះគម្ពីរមរមន ។ ហើយទីបន្ទាល់ផ្ទាល់ខ្លួន ចេញមកពីដួងចិត្តរបស់ពួកគេយ៉ាងច្បាស់ ។ ពួកគេបង្រៀនដោយការផ្លាស់ប្រែចិត្តជឿកាន់តែច្រើន និង ថ្លែងជាសាក្សីដោយអំណាច ។

ខ្ញុំមើលឃើញភស្តុតាងផងដែរថា យើងកំពុងតែធ្វើបានល្អប្រសើរ នៅក្នុងផ្នែកទីបីនៃការសន្យា ដែលយើងបានធ្វើនៅពិធីបុណ្យជ្រមុជទឹក ។ យើងបានធ្វើសេចក្ដីសញ្ញា ប្រកាន់ខ្ជាប់ រក្សាបទបញ្ញត្តិរបស់ព្រះ ដរាបណាយើងនៅរស់ ។

ខ្ញុំបានទៅសួរសុខទុក្ខមិត្តចាស់ម្នាក់នៅក្នុងមន្ទីរពេទ្យ ដែលបានធ្វើរោគវិនិច្ឆ័យឃើញថាមានជម្ងឺមហារីកដែលនឹងស្លាប់ ។ ខ្ញុំបាននាំកូនស្រីពីនាក់ទៅជាមួយ ។ ខ្ញុំមិនរំពឹងថា គាត់ស្គាល់ពួកនាងទេ ។ គ្រួសាររបស់គាត់ឈរនៅជុំវិញគ្រែគាត់ ពេលយើងចូលទៅដល់ ។

គាត់បានមើលមក ហើយញញឹម ។ ខ្ញុំចងចាំជានិច្ចនូវការមើលមករបស់គាត់ ពេលគាត់ឃើញថា ខ្ញុំ និងភរិយា បាននាំកូនស្រីរបស់យើងមកជាមួយ ។ គាត់ប្រាប់ឲ្យពួកគេមកជិតគាត់ ។ គាត់ក្រោកអង្គុយ ឱបពួកគេ ហើយណែនាំដល់គ្រួសាររបស់គាត់ ។ គាត់បាននិយាយអំពីភាពអស្ចារ្យនៃក្មេងស្រីតូចទាំងពីរនាក់នេះ ។ វាដូចជាគាត់កំពុងតែបង្ហាញព្រះនាងទៅកាន់ព្រះរាជវង្សានុវង្សដូច្នោះដែរ ។

ខ្ញុំរំពឹងថាការសួរសុខទុក្ខរបស់យើងនឹងឆាប់ៗ។ ពិតណាស់ ខ្ញុំបានគិតថា គាត់នឿយហត់ហើយ ។ ប៉ុន្តែនៅពេលខ្ញុំបានមើល គឺហាក់ដូចជា រាប់ឆ្នាំបានកន្លងផុតទៅ ។ ជាក់ស្តែងណាស់ គាត់រីករាយ ហើយពេញដោយក្តីស្រឡាញ់ចំពោះយើងគ្រប់គ្នា ។

គាត់មើលទៅរីករាយនឹងគ្រានោះ ដូចជាពេលវេលាត្រូវបានបញ្ឈប់ ។ គាត់បានចំណាយពេលស្ទើរពេញមួយជីវិតគាត់ មើលថែកូនក្មេងសម្រាប់ព្រះអម្ចាស់ ។ គាត់បានដឹងមកពីដំណើររឿងព្រះគម្ពីរមរមនថា ព្រះអង្គសង្គ្រោះដែលបានរស់ឡើងវិញ បាននាំកុមារតូចៗម្នាក់ម្តងៗមកប្រទានពរ ហើយព្រះកន្សែងដោយអំណរ ។[4] ហើយគាត់បានទទួលបទពិសោធន៍ក្តីអំណរនោះយូរល្មម ដែលធ្វើឲ្យគាត់អាចប្រកាន់ខ្ជាប់ នៅក្នុងការបម្រើដោយក្តីស្រឡាញ់របស់ទ្រង់ដល់ទីបំផុត ។ ខ្ញុំបានមើលឃើញអព្ភូតហេតុដូចគ្នានៅក្នុងបន្ទប់គេងរបស់បុរសម្នាក់ ដែលបានផ្តល់ការបម្រើដ៏ស្មោះត្រង់គ្រប់គ្រាន់ល្មម សម្រាប់ខ្ញុំជឿថា គាត់បានធ្វើល្មមគ្រប់គ្រាន់ដើម្បីសម្រាកហើយ ។

ខ្ញុំបានដឹងថា គាត់បានទទួលការព្យាបាលដ៏យូរអង្វែង និង ដោយឈឺចាប់ចំពោះជម្ងឺមួយ ដែលវេជ្ជបណ្ឌិតបានប្រាប់គាត់ថា ដល់ទីបញ្ចប់ហើយ ។ ពួកគេបានឈប់ធ្វើការព្យាបាល និងបាត់បង់ការសង្ឃឹម ។

ភរិយារបស់គាត់បាននាំខ្ញុំទៅកាន់បន្ទប់គេងក្នុងគេហដ្ឋានរបស់ពួកគេ ។ នៅទីនោះ គាត់ទំរេតខ្នងនៅលើគ្រែ ។ គាត់បានពាក់អាវសថ្មី ក្រវ៉ាត់ក និងស្បែកជើងថ្មី ។

គាត់បានឃើញភាពភ្ញាក់ផ្អើលក្នុងកែវភ្នែកខ្ញុំ សើចតិចៗ រួចនិយាយថា « បន្ទាប់ពីអ្នកប្រសិទ្ធពរឲ្យខ្ញុំហើយ ខ្ញុំចង់ត្រៀមខ្លួនដើម្បីឆ្លើយតបចំពោះការហៅ ឲ្យក្រោកឡើង ហើយចេញទៅធ្វើការ » ។ ខ្ញុំអាចមើលឃើញដូច្នោះ គាត់បានត្រៀមខ្លួនសម្រាប់ការសម្ភាសន៍ ដែលគាត់នឹងមានក្នុងពេលឆាប់ៗជាមួយនឹងលោកថៅហ្វាយ ដែលគាត់បានធ្វើការឲ្យយ៉ាងស្មោះត្រង់ ។

គាត់ គឺជាគំរូនៃពួកបរិសុទ្ធថ្ងៃចុងក្រោយដែលបានផ្លាស់ប្រែចិត្តជឿពេញលេញ ដែលខ្ញុំបានជួបជាញឹកញាប់ បន្ទាប់ពីពួកគាត់បានផ្តល់ជីវិតក្នុងការបម្រើដោយការលះបង់ ។ ពួកគាត់បានខំប្រឹងបន្ត ។

ប្រធានម៉ារ៉ុន ជី រ៉មនី បានពិពណ៌នាតាមរបៀបនេះថា ៖ « អ្នកដែលបានផ្លាស់ប្រែចិត្តជឿទាំងស្រុងគឺពុំចង់បានអ្វីដែលផ្ទុយចំពោះដំណឹងល្អព្រះយេស៊ូវគ្រីស្ទសោះឡើយ  ហើយបានជំនួសវិញដោយក្តីស្រឡាញ់របស់ព្រះ ក៏ដូចជាការប្តេជ្ញាចិត្តមុតមាំ និង ការណែនាំក្នុងការរក្សាបទបញ្ញត្តិរបស់ទ្រង់ » ។[5]

ការប្តេជ្ញាចិត្តមុតមាំនោះ មានកាន់តែច្រើនឡើងៗនៅក្នុងពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។ ដូចជាបងស្រីដែលស្វាគមន៍កូនស្រីរបស់ខ្ញុំ និង បុរសដែលពាក់ស្បែកជើងថ្មី ត្រៀមខ្លួនដើម្បីក្រោកឡើងដើរទៅព្រះអម្ចាស់ ដែលពួកគេដើរតាមបញ្ញារបស់ទ្រង់ដល់ទីបំផុត ។ អ្នកទាំងអស់គ្នាបានឃើញហើយ ។

អ្នកអាចមើលវាម្តងទៀត បើអ្នកត្រឡប់ទៅមើលព្រះគម្ពីរមរមន ។ ខ្ញុំនៅតែមានអារម្មណ៍កោតសរសើរក្នុងដួងចិត្ត ពេលខ្ញុំអានពាក្យសម្តីទាំងនេះ របស់អ្នកបម្រើវ័យចំណាស់  និង មានការប្តេជ្ញាចិត្តម្នាក់របស់ព្រះ ថា ៖ « ព្រោះថា ទោះបីនៅពេលនេះសោត រូបរាងរបស់យើងញ័រចំប្រប់ នៅពេលយើងខំនិយាយទៅកាន់អ្នក ប៉ុន្តែព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានជួយគាំទ្រយើង ហើយបានទ្រាំឲ្យយើងនិយាយទៅកាន់អ្នករាល់គ្នា ... » ។[6]

អ្នកអាចមានភាពក្លាហានដូចជាខ្ញុំធ្វើ នៅក្នុងឧទាហរណ៍នៃការប្រកាន់ខ្ជាប់ ដែលមរ៉ូណៃផ្តល់ឲ្យយើង ។ គាត់នៅតែឯងក្នុងការបម្រើគាត់ ។ គាត់បានដឹងថា ទីបញ្ចប់នៃជីវិតជិតមកដល់ហើយ ។ ប៉ុន្តែចូរស្តាប់នូវអ្វីដែលគាត់បានសរសេរសម្រាប់ជាប្រយោជន៍ដល់ប្រជាជន ដែលពុំទាន់កើតនៅឡើយ និងកូនចៅទាំងឡាយនៃសត្រូវខាងជីវិតរមែងស្លាប់របស់គាត់ថា ៖ « មែនហើយ ចូរមករកព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ ហើយចូរលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធចុះ ហើយស្រឡាញ់ព្រះឲ្យអស់ពីសមត្ថភាព អស់ពីគំនិត និង អស់ពីកម្លាំងរបស់អ្នក នោះព្រះគុណរបស់ទ្រង់ល្មមដល់អ្នកហើយ ដោយសារព្រះគុណនៃព្រះ នោះអ្នករាល់គ្នាអាចបានល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ » ។[7]

មរ៉ូណៃបានធ្វើសាក្សីជាការនិយាយលាក្នុងការបម្រើ និងជីវិតរបស់គាត់ ។ គាត់បានជម្រុញទឹកចិត្តអំពីសេចក្តីសប្បុរសដូចជាពួកព្យាការីនៅពេញគម្ពីរមរមន ។ គាត់បានបន្ថែមសាក្សីរបស់គាត់ អំពីព្រះអង្គសង្គ្រោះ នៅពេលគាត់ហៀបស្លាប់ ។ គាត់គឺជាកូនព្រះដែលបានផ្លាស់ប្រែចិត្តជឿពិត ដូចជាយើង អាច ៖ ពេញដោយសេចក្តីសប្បុរស ខ្ជាប់ខ្ជួន និង ពុំខ្លាចក្នុងនាមជាសាក្សីរបស់ព្រះអង្គសង្គ្រោះ និង ដំណឹងល្អរបស់ទ្រង់ ហើយប្តេជ្ញាចិត្ត ដើម្បីប្រកាន់ខ្ជាប់ដរាបដល់ចុងបំផុតផងដែរ ។ មរ៉ូណៃ បង្រៀនយើងនូវអ្វីដែលតម្រូវពីយើង ។ គាត់បាននិយាយថា ជំហានទីមួយ ដើម្បីមានការផ្លាស់ប្រែចិត្តជឿពេញលេញ គឺជំនឿ ។ ការសិក្សាព្រះគម្ពីរមរមនប្រកបដោយការអធិស្ឋាន នឹងស្ថាបនាជំនឿទៅលើព្រះជាព្រះបិតា ព្រះបុត្រាតែមួយរបស់ទ្រង់ និង ដំណឹងល្អរបស់ទ្រង់ ។ វានឹងស្ថាបនាជំនឿរបស់អ្នក ទៅលើពួកព្យាការីរបស់ព្រះ ទាំងបុរាណកាល និង សម័យទំនើប ។

គម្ពីរនេះ អាចនាំអ្នកខិតទៅកាន់តែជិតនឹងព្រះជាងគម្ពីរផ្សេងៗទៀត ។ វាអាចផ្លាស់ប្រែជីវិតឲ្យកាន់តែប្រសើរ ។ ខ្ញុំលើកទឹកចិត្តអ្នកឲ្យធ្វើអ្វីដែលដៃគូផ្សព្វផ្សាយសាសនារបស់ខ្ញុំបានធ្វើ ។ នៅពេលគាត់រត់ចេញពីផ្ទះកាលពីយុវវ័យ មាននរណាម្នាក់បានដាក់គម្ពីរមរមននៅក្នុងប្រអប់មួយ ដែលគាត់បានយកទៅជាមួយគាត់ ក្នុងការស្រាវជ្រាវរកសុភមង្គលបន្ថែម ។

ជាច្រើនឆ្នាំកន្លងទៅ ។ គាត់បានផ្លាស់ពីកន្លែងមួយទៅកន្លែងមួយ ទូទាំងពិភពលោក ។ គាត់នៅឯកោរ ហើយពុំសប្បាយចិត្ត ថ្ងៃមួយពេលគាត់បានឃើញប្រអប់ ។ ប្រអប់នោះពេញទៅដោយរបស់របរដែលគាត់បានយកទៅជាមួយគាត់ ។ នៅក្រោមប្រអប់ គាត់បានឃើញគម្ពីរមរមន ។ គាត់បានអានការសន្យានៅក្នុងនោះ រួចសាកល្បង។ គាត់បានដឹងថាវាគឺជាការពិត ។ សាក្សីនោះបានផ្លាស់ជីវិតរបស់គាត់ ។ គាត់បានរកឃើញសុភមង្គល ហួសពីសុបិនដែលគាត់ចង់បានទៅទៀត ។

គម្ពីរមរមនរបស់អ្នកប្រហែលជាពុំបានអានច្រើន តាមដែលអ្នកគួរអាននោះទេ ព្រោះតែការទទួលខុសត្រូវ និង សកម្មភាពជាច្រើនប្រចាំថ្ងៃរបស់អ្នក ។ ខ្ញុំសូមអង្វរដល់អ្នកឲ្យសិក្សាញឹកញាប់ពីទំព័រគម្ពីរមរមន ។ វាមាននូវភាពពេញលេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ដែលជាផ្លូវតែមួយគត់ដើម្បីត្រឡប់ទៅផ្ទះនៅជាមួយព្រះវិញ ។

ខ្ញុំសូមបន្សល់ទុកនូវសាក្សីពិតរបស់ខ្ញុំ ថា ព្រះមានព្រះជន្មរស់ ហើយនឹងឆ្លើយតបការអធិស្ឋានរបស់អ្នក ។ ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះអង្គសង្គ្រោះនៃពិភពលោក ។ ព្រះគម្ពីរមរមនពិត និងជាសាក្សីមុតមាំថាទ្រង់មានព្រះជន្មរស់ ហើយថា ទ្រង់គឺជាព្រះអង្គសង្គ្រោះដែលបានរស់ឡើងវិញ និងមានព្រះជន្មរស់របស់យើង។

ព្រះគម្ពីរមរមន គឺជាសាក្សីពិត និងដ៏មានតម្លៃអំពីព្រះយេស៊ូវគ្រីស្ទ ។ នៅក្នុងព្រះនាមពិសិដ្ឋនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. ម៉ូសាយ 18:9 ។
2. ម៉ូសាយ 2:17 ។
3. មរ៉ូណៃ 7:47 ។
4. សូមមើល នីហ្វៃទី3 17:21–22 ។
5. Marion G. Romney, នៅក្នុង Conference Report, ខែតុលា ឆ្នាំ 1963 ទំព័រ 23 ។
6. ម៉ូសាយ 2:30 ។
7. មរ៉ូណៃ 10:32 ។